# អនុក្រឹត្យលេខ ០៨ អនក្រ.បក
## ស្តីពីការផ្តល់បណ្ណសំគាល់យានយន្តផ្លូវគោក

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងក្រឹត្យលេខ ៦៨ ក្រ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីចរាចរផ្លូវគោក
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៩៩

## សម្រេច

## ជំពូក I
## បទប្បញ្ញត្តិទូទៅ

មាត្រា ១ ._ កំណត់នីតិវិធីស្តីពីការផ្តល់បណ្ណសំគាល់ និង ផ្លាកលេខយានយន្តផ្លូវគោក ដើម្បី :

- ធានាឲ្យបានរឹងមាំនូវសន្តិសុខ សណ្តាប់ធ្នាប់ និង សុវត្ថិភាពសង្គម ។
- ធានាកម្មសិទ្ធិជូនម្ចាស់យានយន្តផ្លូវគោកឲ្យបានត្រឹមត្រូវស្របច្បាប់ជាធរមាន ។
- ធានាដល់ការប្រមូលប្រាក់ចំណូលជូនរដ្ឋ ឲ្យមានប្រសិទ្ធភាពដោយទប់ស្កាត់នូវអំពើគេចពន្ធ និងការក្លែងបន្លំផ្សេងៗ ។
- ផ្តល់ភាពងាយស្រួលដល់អ្នកប្រើប្រាស់យានយន្តគ្រប់ប្រភេទ ក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងការទិញដូរយានយន្ត ។

មាត្រា ២ ._ ក្នុងគោលបំណងនៃអនុក្រឹត្យនេះ ៖

ក-ពាក្យថា "យានយន្តផ្លូវគោក" ហៅកាត់ថា "យានយន្ត" គឺជាយានជំនិះទាំងឡាយណាដែលធ្វើចលនាដោយគ្រឿងម៉ាស៊ីន សំរាប់ដាក់ឲ្យធ្វើចរាចរនៅលើផ្លូវសាធារណៈ ។

ខ- ពាក្យថា " ម្ចាស់ហាងលក់យានយន្ត " ហៅកាត់ថា " ម្ចាស់ហាង " គឺជាអាជីវករលក់យានយន្ត នៅក្នុងរាជធានីភ្នំពេញ ឬ នៅតាមខេត្ត-ក្រុង ដែលមានច្បាប់អនុញ្ញាតិត្រឹមត្រូវពីអាជ្ញាធរមានសមត្ថកិច្ចអោយប្រកបអាជីវកម្មលក់យានយន្ត ។

គ- ពាក្យថា " វិក្កយបត្រលក់យានយន្ត " គឺជាសក្ខីបត្របញ្ជាក់ការលក់យានយន្តដែលមានសណ្ឋានឯកភាពទូទាំងប្រទេស និងមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយប្រើប្រាស់នៅគ្រប់ហាងលក់យានយន្ត ។

ឃ- ពាក្យថា " ប្លាកដែលបង់ពន្ធគយ " គឺជាសក្ខីបត្រមានលេខរៀងសំគាល់ សំរាប់បញ្ជាក់ថាយានយន្តបានបង់ពន្ធគយរួចហើយ ។ ប្លាកដែលបង់ពន្ធគយមួយសំរាប់តែយានយន្តមួយគ្រឿងតែប៉ុណ្ណោះ ។

ង- ពាក្យថា " ពាក្យសុំប័ណ្ណសំគាល់យានយន្ត " គឺជាសំណុំឯកសារដែលចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូនសំរាប់ការស្នើសុំប័ណ្ណសំគាល់យានយន្ត ។

ច- ពាក្យថា " ផ្លាកលេខ " គឺជាផ្លាកធ្វើអំពីដែកបង្ហាញលេខសំគាល់ ដែលមានសរសេរលេខសំគាល់យានយន្តនៅលើនោះ ហើយដែលចេញដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។

## ជំពូក II

## ភារកិច្ចរបស់ម្ចាស់ហាងលក់យានយន្ត និង អ្នកទិញយានយន្ត

មាត្រា ៣ ._

ក- នៅពេលលក់យានយន្ត ម្ចាស់ហាងត្រូវផ្តល់វិក្កយបត្រមួយសន្លឹក ដោយប្រគល់ជូនអ្នកទិញទុកជាភ័ស្តុតាង ។

ខ- អ្នកទិញត្រូវបំពេញពាក្យសុំប័ណ្ណសំគាល់យានយន្ត ដោយចុះហត្ថលេខាក្នុងពាក្យសុំនៅចំពោះមុខម្ចាស់ហាង ដោយភ្ជាប់ជាមួយច្បាប់ដើមសំគាល់ខ្លួន ឬអត្តសញ្ញាណប័ណ្ណថតចំលងមួយសន្លឹក ។

គ- ម្ចាស់ហាងត្រូវរៀបចំសំណុំដើម នៃពាក្យសុំប័ណ្ណសំគាល់យានយន្តជំនួសអ្នកទិញ ទៅនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការ និង ដឹកជញ្ជូនអោយបានឆាប់រហ័សបំផុត ។ សំណុំដើមនៃពាក្យសុំប័ណ្ណសំគាល់យានយន្តមាន :

- ពាក្យសុំរបស់ម្ចាស់យានយន្តដែលបានបំពេញរួចហើយ
- អត្តសញ្ញាណប័ណ្ណរបស់អ្នកទិញ ឬ ច្បាប់សំគាល់ខ្លួនថតចំលង ដែលថតចម្លងចំនួនមួយសន្លឹក ។
- ប្លាកដែលបង់ពន្ធគយមួយសន្លឹក ដែលមានទិដ្ឋាការត្រួតពិនិត្យរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។
- វិក្កយបត្រមួយសន្លឹក ។
- ឯកសារពាក់ព័ន្ធផ្សេងៗ បើសិនជាមាន ។

ឃ- ក្រោយពីអ្នកទិញបានបំពេញបែបបទសុំប័ណ្ណសំគាល់យានយន្តរួចហើយ ម្ចាស់ហាងត្រូវបំពាក់ផ្លាកលេខបណ្តោះអាសន្នដែលចេញដោយក្រសួងសាធារណការនិងដឹកជញ្ជូន អោយយានយន្ត ដើម្បីអោយអ្នកទិញ ដែលជាម្ចាស់យានយន្ត មានលទ្ធភាពប្រើប្រាស់យានយន្ត ក្នុងរយៈពេលយ៉ាងយូរ ៣០ ថ្ងៃ នៅរាជធានីភ្នំពេញ និង ៤០ ថ្ងៃនៅតាមខេត្ត-ក្រុង ។

ង- ចំពោះយានយន្តដែលនាំចូលជាលក្ខណៈបុគ្គល ត្រូវបំពេញបែបបទដូចមានចែងក្នុងចំណុច "គ" នៃមាត្រានេះ ។

ច- ចំពោះយានយន្តផលិតក្នុងស្រុក ត្រូវចែងដោយអនុក្រឹត្យមួយដោយឡែក ។

មាត្រា ៤ ._

ក- ម្ចាស់ហាងអាចចាត់តាំងតំណាងម្នាក់អោយបំពេញការពិធីសុំចុះបញ្ជី និងសុំផ្លាកលេខនៅអគ្គនាយកដ្ឋានដឹកជញ្ជូនបាន ។ ក្នុងករណីនេះ ម្ចាស់ហាងចេញលិខិតឧទ្ទេសនាមតំណាងមួយសន្លឹក ទៅអគ្គនាយកដ្ឋានដឹកជញ្ជូន ។

ខ- ម្ចាស់ហាងត្រូវបញ្ជូនមកអគ្គនាយកដ្ឋានដឹកជញ្ជូន នូវឯកសារមួយចំនួនទៀតដូចជា :

- នាម និង គោត្តនាមនៃម្ចាស់ហាង
- ឈ្មោះហាងលក់យានយន្ត
- អាសយដ្ឋានរបស់ហាងលក់យានយន្ត
- ចំលងហត្ថលេខា និងត្រារបស់ម្ចាស់ហាង ឬអ្នកទទួលខុសត្រូវដែលមានសិទ្ធិចុះហត្ថលេខាលើវិក្កយបត្រ ។
- លិខិតអនុញ្ញាតអោយប្រកបអាជីវកម្មលក់យានយន្តមួយសន្លឹក និងលិខិតបង់ប៉ាតង់ថតចំលងមួយសន្លឹក ។

មាត្រា ៥ ._ ម្ចាស់ហាងត្រូវធានាអោយអ្នកទិញត្រឡប់មកយកប័ណ្ណសំគាល់ និងផ្លាកលេខយានយន្តពីហាងរបស់ខ្លួនក្នុងរយៈពេលយ៉ាងយូរបំផុត ៣០ថ្ងៃ នៅរាជធានីភ្នំពេញ និង ៤០ ថ្ងៃនៅតាមខេត្ត-ក្រុង ។

## ជំពូក III

## ភារកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ច

មាត្រា ៦ ._

ក- គ្មានប្រភេទយានយន្តណាមួយត្រូវបានអោយរួចពន្ធទេ ។ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវមានវិធានការម៉ឺងម៉ាត់ដើម្បីទប់ស្កាត់ការគេចពន្ធ ឬការក្លែងបន្លំសន្លឹកពន្ធ ដោយត្រូវចុះត្រួតពិនិត្យនៅតាមហាង លក់យានយន្តជាប្រចាំ ។

ខ- ចំពោះយានយន្តដែលជាប់ពន្ធ ជាបន្ទុករបស់រដ្ឋ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវចេញលិខិតបញ្ជាក់ការបង់ពន្ធជាបន្ទុករបស់រដ្ឋមួយសន្លឹក សំរាប់យានយន្តមួយគ្រឿង ដែលនៅក្នុងលិខិតនេះ ត្រូវមានបញ្ជាក់ ម៉ាក- ពណ៌- លេខតួ- លេខម៉ាស៊ីន- ឆ្នាំផលិត-ម្ចាស់យានយន្ត

អាសយដ្ឋានរបស់ម្ចាស់យានយន្តអោយបានច្បាស់លាស់ ។ ចំពោះរថយន្តសាលារៀន អាជីវកម្ម ត្រូវបញ្ជាក់អំពីចំណុះផ្ទុកអ្នកដំណើរ ចំពោះរថយន្តដឹកអ្នកដំណើរ និង ចំណុះផ្ទុកទំនិញចំពោះរថយន្តដឹកទំនិញ ។

ត- ចំពោះយានយន្តដែលត្រូវបានអនុញ្ញាតអោយនាំចូលជាបណ្ដោះអាសន្ន តែមិនត្រូវជាប់ពន្ធ ទោះជាបន្ទុករបស់រដ្ឋក៏ដោយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចេញលិខិតបញ្ជាក់ការបង់ពន្ធ និង បញ្ជាក់ការលើកនាំចូលជាបណ្ដោះអាសន្ន មួយលើក សំរាប់យានយន្តមួយគ្រឿង ។ នៅក្នុងលិខិតនេះក្រៅពីការបញ្ជាក់ភិនភាគយានយន្ត និង ម្ចាស់យានយន្តត្រូវមានបញ្ជាក់ រយៈពេល ដែលយានយន្តត្រូវបានអនុញ្ញាតអោយប្រើប្រាស់បណ្ដោះអាសន្ន នៅក្នុងព្រះរាជាណាចក្រកម្ពុជា អោយបានច្បាស់លាស់ ។ នៅពេលផ្ទេរកម្មសិទ្ធិអោយទៅបុគ្គលដែលគ្មាន អភ័យឯកសិទ្ធិ ម្ចាស់យានយន្តត្រូវបង់ពន្ធជូនរដ្ឋតាមច្បាប់ជាធរមាន ។

មាត្រា ៧ ._ ក្រសួងសាធារណការ និងដឹកជញ្ជូន ត្រូវចេញសារាចរណែនាំលំអិតបន្ថែមស្ដីពីការអនុវត្តអនុក្រឹត្យ និងត្រូវរាយការណ៍ទៅក្រសួងពាក់ព័ន្ធក្នុងករណីមានបាតុភាពផ្សេងៗ ។ ក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវផ្ដល់បញ្ជីនៃការផ្ដល់ផ្លាកលេខបណ្ដោះអាសន្ននិងផ្លាកលេខយានយន្តមកក្រសួងមហាផ្ទៃជារៀងរាល់សប្ដាហ៍ ។

មាត្រា ៨ ._ នៅពេលធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្តជាលើកដំបូងឬជាប្រចាំ ក្រសួងសាធារណការ និងដឹកជញ្ជូន មានសិទ្ធិដកហូត ឬមិនផ្ដល់ ផ្លាកលេខជូនចំពោះយានយន្តដែលពិនិត្យឃើញថា ពុំមានលក្ខណៈបច្ចេកទេស និងយថាប្រភេទ សមស្របតាមការកំណត់របស់ក្រសួង ។

មាត្រា ៩ ._ ក្រសួងពាណិជ្ជកម្មត្រូវផ្ដល់បញ្ជីឈ្មោះ ហាងលក់យានយន្ត អោយទៅក្រសួងសាធារណការ និងដឹកជញ្ជូនដើម្បីងាយស្រួលក្នុងការតាមដាន ។

មាត្រា ១០ ._ ក្រសួងមហាផ្ទៃត្រូវមានវិធានការម៉ឺងម៉ាត់ ដើម្បីធានាអោយគ្រប់យានយន្តដែលធ្វើចរាចរនៅលើផ្លូវសាធារណៈ មានពាក់ផ្លាកលេខត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ។

មាត្រា ១១ ._ ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចត្រួតពិនិត្យឃើញមានការគេចពន្ធ ឬ ការក្លែងបន្លំឯកសារលិខិតនៅក្នុងហាងលក់យានយន្តណាមួយនោះ ម្ចាស់ហាងនោះត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

## ជំពូក IV

## អន្តរប្បញ្ញត្តិ

មាត្រា ១២ ._ ក្នុងរយៈពេលមួយឆ្នាំ គិតចាប់តាំងពីថ្ងៃដែលអនុក្រឹត្យនេះ ចូលជាធរមាន ម្ចាស់យានយន្តទាំងឡាយ ដែលកំពុងធ្វើចរាចរនៅលើផ្លូវសាធារណៈ ហើយដែលពុំទាន់មានផ្លាកលេខ ត្រូវដាក់ពាក្យសុំប័ណ្ណសំគាល់យានយន្តនៅអគ្គនាយកដ្ឋានដឹកជញ្ជូន និង ត្រូវមានពាក់ផ្លាកលេខអោយបានគ្រប់សព្វគ្រប់ជាក់ហើយក្នុងរយៈពេលដូចមានចែងខាងលើ ។ ផុតរយៈពេលនេះក្រសួងសាធារណការ

និង ពីរកង់ក្លួន ពីមិនទាន់បានបណ្ណសំគាល់ជូនអ្នកបើកបរយន្តហោះ ដែលគ្មានប្រភពចេញពីរោងចក្រផលិតយាន យន្តរៀប ។ លើកលែងតែយានយន្តដែលនាំចូលជាលក្ខណៈបុគ្គលដែលមានកំណត់ដោយ ឡែករបស់ក្រសួងសាធារណការ និង ដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ជំពូក V

## អវសានបញ្ញត្តិ

មាត្រា ១៣ ._ រាល់បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ១៤ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន និងស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តន៍អនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ១៥ ._ អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា-និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ០៦ អនក្រ.តត

## ស្តីពីការដាក់អោយចូលនិវត្តន៍របស់មន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦ នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់មន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ,

## សំរេច

មាត្រា ១ ._ ត្រូវបានដាក់អោយចូលនិវត្តន៍នូវមន្ត្រីរាជការ ដូចមានរាយនាមខាងក្រោមនេះ ÷

១- លោក ប្រាក់ ឡេង បច្ចុប្បន្នប្រធានមន្ទីរនៃទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។